

# តាំតាំ


Amrin Pisey

May Sak



Let's Read

The Asia Foundation



តាំតាំ រស់នៅជាមួយម្តាយគេក្នុងផ្ទះមួយដែលមិននៅឆ្ងាយប៉ុន្មានពីភ្នំ។ តាំតាំ ស្រលាញ់ម្តាយរបស់គេណាស់ ប៉ុន្តែ គេមិនចូលចិត្តពេលដែល ម្តាយគេស្តីប្រដៅឱ្យគេទេ និងមិនចូលចិត្តជួយធ្វើការងារផ្ទះទេ។







ជារឿយៗម្ដាយគេហាមគេ ៖
«តាំតាំ ! កុំញ៉ាំច្រើនពេកកូនប្រយ័ត្នឈឺពោះ!»
«តាំតាំ !កុំលេងទឹកភ្លៀងកូនប្រយ័ត្នផ្ដាសាយ។»
ពេលខ្លះម្ដាយរបស់តាំតាំ ប្រើគេឱ្យធ្វើការងារផ្ទះ ៖ «តាំតាំ !
ជួយដងទឹកដាក់ពាងផងកូន។»



ថ្ងៃមួយ តាំតាំ ចង់ឡើងទៅលើភ្នំដើម្បីគេចចេញពីម្ដាយមួយថ្ងៃ ដើម្បីកុំឱ្យគាត់ស្ដីបន្ទោស។



នៅតាមផ្លូវ តាំតាំពិតជារីករាយណាស់។ ប៉ុន្តែ ពេលដើរចេញបានឆ្ងាយពីផ្ទះបន្តិច គេចាប់ផ្ដើមអស់កម្លាំង និងកូរពោះគ្រូកៗ។



ពេលនោះ តាំតាំ បានប្រទះឃើញវាលមួយដែលមានពោត
យ៉ាងច្រើននៅតាមផ្លូវនោះ។ តាំតាំ សប្បាយចិត្តណាស់ គេ
គិតថាគេលើកនេះគេនឹងញុំាពោតនេះឱ្យច្រើន ព្រោះមិនមាន
នរណាហាមគេទៀតទេ។



ប៉ុន្តែក្រោយពីញ៉ាំហើយ គេចាប់ផ្តើមហល់ និងឈឺពោះ។ តាំតាំក្តោបពោះ និងនឹកឃើញដល់ពាក្យម្តាយ៖ ”ឃើញទេ ម៉ែប្រាប់ថាកុំឱ្យញ៉ាំច្រើនពេក។ ម៉ែថា ដើរចុះឡើងបន្តិចទៅ នឹងបាត់ហល់ហើយ។។”



ក្រោយពីសម្រាកបន្តិច តាំតាំ បាត់ហល់ហើយ ប៉ុន្តែគេនៅមិនទាន់ចង់ទៅផ្ទះនៅឡើយទេ។ តាំតាំ ដើរបានបន្តិចស្រាប់តែតាំតាំស្រេកទឹក។

ចៃដន្យគេបានជួបនឹងកូនខ្លាឃ្មុំមួយកំពុងជួយម្ដាយរែកទឹក ហើយ តាំតាំក៏សួររកកន្លែងដែលគេដងទឹក។ ពួកគេក៏ចង្អុលទៅទឹកអូរមួយ។



តាំតាំលួចសួរទៅកូនខ្លាឃ្មុំ ៖ «ឯងជួយការងារម្ដាយបែបនេះ មិនធុញទេឬ?»
កូនខ្លាឃ្មុំតប ៖ «អត់ទេ! គាត់មើលថែយើងតាំងពីតូចហើយ ដូច្នេះយើងត្រូវចេះជួយគាត់វិញនៅពេលយើងធំ ព្រោះគាត់ហត់ណាស់។»



ពេលនោះ តាំតាំ ចាប់ផ្តើមនឹកឃើញដល់ពេលដែលម្តាយប្រើ ឱ្យគេជួយដងទឹកតែគេមិនធ្វើ។



កូនខ្លាឃ្មុំក៏ចេញទៅបាត់។ ក្រោយពីផឹកទឹករួច គេក៏នៅតែ
មិនទាន់ចង់ទៅផ្ទះ។ ដូច្នេះគេក៏បន្តដំណើរទៅមុខទៀត។
ពេលដើរដល់ជើងភ្នំ ស្រាប់តែមានភ្លៀងធ្លាក់មួយមេយ៉ាងធំ។
តាំតាំ សប្បាយចិត្តណាស់ ព្រោះពេលនេះគេអាចលេងទឹកភ្លៀង
ដោយមិនមានអ្នកហាមឡើយ។



តាំតាំ លេងភ្លៀងមួយស្របក់រហូតដល់ឆ្អែត ប៉ុន្តែភ្លៀងមិនទាន់រាំងនៅឡើយទេ។
តាំតាំ រងារញ៉ូរខ្លួន និងកណ្តាសពីរបីដង។
គេចាប់ផ្តើមនឹកដល់ពាក្យម្តាយគេ «តាំតាំ! កុំលេងទឹកភ្លៀងកូនប្រយ័ត្នផ្តាសាយ។»



តាំតាំ អង្គុយឱបដៃនៅក្រោមដើមឈើមួយទាំងមេឃកំពុងភ្លៀង។ គេក្រឡេកឃើញឪចាប និងកូនចាប កំពុងជជែកគ្នា។

កូនចាប៖ កូនរងារណាស់ពុក!

ឪចាប៖ ចាំពុកបាំងភ្លៀង កុំឱ្យរងារកូន!

ឃើញបែបនោះ តាំតាំ នឹកដល់ម្ដាយគេជាខ្លាំង។



ពេលនេះតាំតាំចង់ត្រឡប់ទៅផ្ទះវិញហើយ។ ប៉ុន្តែគេមិនទាន់
អាចទៅបានទេ ដូច្នេះគេក៏ជ្រកក្រោមដើមឈើ គិតថាមេឃ
រាំងភ្លៀងនឹងអាងត្រឡប់ទៅផ្ទះវិញ។
ពេលនោះ គេក៏បានឮសំឡេងស្រែកហៅឈ្មោះគេល្វើយៗ
ដោយសារតាំតាំ ហត់ពេល គេក៏បានគេងលក់ទាំងមិនដឹងខ្លួន។



នាព្រឹកថ្ងៃបន្ទាប់ ពេលភ្ញាក់ពីគេងវិញស្រាប់តែ តាំតាំភ្ញាក់ព្រើត
ព្រោះគេនៅលើគ្រែក្នុងបន្ទប់គេងរបស់គេ។
តាំតាំ ងាកមកឃើញម្ដាយរបស់គេជាមួយបបរក្ដៅមួយចាន។



ម្ដាយក៏រៀបរាប់អំពីការដើររក តាំតាំ។
ពេលនេះ តាំតាំ ដឹងហើយថាម្ដាយរបស់គេតែងតែស្រឡាញ់
និងខ្វល់បារម្ភពីគេ។
ចាប់តាំងពីពេលនោះមក តាំតាំ ជួយតែងធ្វើការងារម្ដាយ។
ពួកគេក៏រស់នៅជាមួយគ្នាយ៉ាងសប្បាយរីករាយ។

Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**

*តាំតាំ (Tamtam)*, Author: Amrin Pisey. Illustrator: May Sak. Published by The Asia Foundation - Let's Read, © The Asia Foundation - Let's Read. Released under CC BY-NC 4.0.

This work is a modified version of the original story. © The Asia Foundation, 2021. Some rights reserved. Released under CC BY-NC 4.0.

For full terms of use and attribution,
http://creativecommons.org/licenses/by-nc/4.0/